ធ៧-០៧-១៦៤ ប្រ.ក

# ប្រកាស
# ស្តីពី
# ការប្រើប្រាស់ភាសា ឯកត្តារូបិយវត្ថុ និងអត្រាប្តូរប្រាក់សម្រាប់ចុះកិច្ចបញ្ជិកា គណនេយ្យ និងរាយការណ៍

**ប្រការ ១**.-

គ្រប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុត្រូវចុះកិច្ចបញ្ជិកាគណនេយ្យរបស់ខ្លួនជាប្រាក់រៀល ឬប្រាក់ដុល្លារអាមេរិកដោយប្រើអត្រាប្តូរប្រាក់មធ្យមផ្លូវការដែលប្រកាសដោយធនាគារជាតិនៃកម្ពុជាតាមគ្រានីមួយៗ។

**ប្រការ ២**.-

រាល់លិខិតបទដ្ឋាននានាដែលធ្វើឡើងសម្រាប់ទំនាក់ទំនងជាមួយធនាគារជាតិនៃកម្ពុជា ត្រូវតែប្រើជាភាសាខ្មែរ។

**ប្រការ ៣**.-

គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុណាដែលមិនគោរពតាមប្រកាសនេះនឹងត្រូវរងទណ្ឌកម្មខាងវិន័យដូចមានចែងក្នុងមាត្រា ៥២ នៃច្បាប់ស្តីពីគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ។

**ប្រការ ៤**.-

ប្រកាសលេខធ ៥-៩៣-២០៨ ប្រក ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការប្រើប្រាស់ភាសា និងឯកត្តារូបិយវត្ថុសម្រាប់ចុះកិច្ចបញ្ជិកាគណនេយ្យ និងរាយការណ៍ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៥**.-

អគ្គនាយកដ្ឋាន អគ្គលេខាធិការដ្ឋាន អគ្គាធិការដ្ឋាន អគ្គបេឡា គ្រប់នាយកដ្ឋាន និង អង្គភាពក្រោមឱវាទ ធនាគារជាតិនៃកម្ពុជា និងគ្រប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុនៅក្រោមអាណាព្យាបាលធនាគារជាតិនៃកម្ពុជា ត្រូវអនុវត្តម៉ឺងម៉ាត់នូវប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន។

**ប្រការ ៦**.-

ប្រកាសនេះមានប្រសិទ្ធភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៧

**ទេសាភិបាល**

ហត្ថលេខា និងត្រា : **ជា ចាន់តូ**